**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :...២៣....អនក្រ.បក**

**អនុក្រឹត្យ**

**ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភចំពោះប្រធានការិយាល័យ**

**ប្រជាពលរដ្ឋ របស់រដ្ឋបាលស្រុកសាគល្បង ស្រុកសៀមរាប**

**ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ១០/នស/៩៤. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥. ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៩ និង ត្រូវបានកែប្រែ ដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០. ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញសេចក្តីសំរេចលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាលស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ គ្រប់គ្រងរដ្ឋបាល ស្រុកសៀមរាប ខេត្តសៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

**<u>សំរេច</u>**

**មាត្រា ១.-** ត្រូវបានកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែ ចំពោះប្រធានការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាល ស្រុកសាគល្បង ស្រុកសៀមរាប ខេត្ត សៀមរាប និង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ស្មើនឹងប្រាក់ បំណាច់មុខងារកម្រិត ១ របស់អភិបាលរងស្រុក ខ័ណ្ឌ ។

**មាត្រា ២.-** ប្រាក់ឧបត្ថម្ភដែលបានកំណត់ក្នុងមាត្រា ១ ខាងលើនឹងត្រូវអនុវត្តចំពោះប្រធានការិយាល័យប្រជាពលរដ្ឋគ្រប់ស្រុក ខ័ណ្ឌ ដែលរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងតាមគំរូនៃសេចក្តីសំរេចលេខ ៤៧ សសរ ចុះថ្ងៃទី១១ ខែ មិថុនា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ។

**មាត្រា ៣.-** ប្រាក់ឧបត្ថម្ភរបស់ប្រធានការិយាល័យប្រជាពលរដ្ឋ ត្រូវផ្តល់ជូនតែក្នុងរយៈពេលនៃមុខតំណែង និង ត្រូវចាប់អនុវត្តក្រោយពីមានដីកាតែងតាំងជាផ្លូវការរបស់អភិបាលខេត្ត ក្រុង ។

**មាត្រា ៤.-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែ ០៣.....ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

***កន្លែងទទួល:***

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ដូចចែងក្នុងប្រការ ៥*

*-រាជកិច្ច*

*-ឯកសារ-កាលប្បវត្តិ*